# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ៩៤២ សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការបែងចែកភារកិច្ចរបស់អនុរដ្ឋលេខាធិការ
## នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៤ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងអនុរដ្ឋលេខាធិការ នៃក្រសួង និង រដ្ឋលេខាធិការដ្ឋាននៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែមនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និង រតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៩៤០ សហវ.ប្រក ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពី[illegible] ភារកិច្ចរបស់ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតម្រូវការចាំបាច់ក្នុងការធានាការដឹកនាំឱ្យបានល្អ និងប្រកបដោយប្រសិទ្ធភាព[illegible] ដែលរាជរដ្ឋាភិបាលនិងស្ថាប័ននីតិប្បញ្ញត្តិប្រគល់ជូនឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី[illegible] ទទួលខុសត្រូវចំពោះមុខនាយករដ្ឋមន្ត្រី និងរដ្ឋសភាលើវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

# សម្រេច

**ប្រការ១:** **កំណត់ភារកិច្ចតាមក្របខ័ណ្ឌការងារជូនអនុរដ្ឋលេខាធិការ ដូចតទៅ :**

**ក.** ឯកឧត្តម **ញាណ ឡេង** អនុរដ្ឋលេខាធិការ ទទួលបន្ទុកការងារ ដូចខាងក្រោម:

១- ការគ្រប់គ្រងក្រសួង ស្ថាប័ន ក្នុងឋានៈជាអភិបាលហិរញ្ញវត្ថុ: គ្រប់គ្រងការងារចំណាយ ការងារប្រមូលចំណូល និង ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៃក្រសួងធនធានទឹកនិងឧតុនិយម ។

២- ការគ្រប់គ្រងការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត: គ្រប់គ្រងការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកំពង់ធំ ខេត្តឧត្តរមានជ័យ និង ខេត្តព្រះវិហារ ។

៣- ការងារដោយឡែក: ការងារដោះស្រាយផលប៉ះពាល់ដោយសារគំរោងអភិវឌ្ឍន៍, ជួយរដ្ឋលេខាធិការទទួលបន្ទុកការងារគោលនយោបាយចំណាយលើកិច្ចការហិរញ្ញកិច្ច និង ជួយកិច្ចការផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន ។

**ខ.** ឯកឧត្តម **ស្វេង ម៉េងគា** អនុរដ្ឋលេខាធិការ ទទួលបន្ទុកការងារ ដូចខាងក្រោម:

១- ការគ្រប់គ្រងក្រសួង ស្ថាប័ន ក្នុងឋានៈជាអភិបាលហិរញ្ញវត្ថុ: គ្រប់គ្រងការងាចំណាយ ការងារប្រមូលចំណូល និង ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល និង ក្រសួងយុត្តិធម៌ ។

២- ការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត: គ្រប់គ្រងការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកែប, ខេត្តកំពត និង ខេត្តព្រះសីហនុ ។

៣- ការងារដោយឡែក: គ្រប់គ្រងការងារដែលពាក់ព័ន្ធនឹងគំរោងវិស័យអគ្គិសនី ជួយការងាររដ្ឋលេខាធិការទទួលបន្ទុកគោលនយោបាយចំណូល ជាពិសេសចំណូលមិនមែនសារពើពន្ធ និង ជួយកិច្ចការផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធាន ស្ថាប័ន។

**គ.** ឯកឧត្តម **ឆាន់ ទឡ្ហន**: អនុរដ្ឋលេខាធិការ ទទួលបន្ទុកការងារ ដូចខាងក្រោម:

១- ការគ្រប់គ្រងក្រសួង ស្ថាប័ន ក្នុងឋានៈជាអភិបាលហិរញ្ញវត្ថុ: គ្រប់គ្រងការងារចំណាយ ការងារប្រមូលចំណូលនិងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៃក្រសួង ស្ថាប័ន រួមមាន ក្រសួងពាណិជ្ជកម្ម នឹង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

២- ការគ្រប់គ្រងការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត: គ្រប់គ្រងការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានីភ្នំពេញ ខេត្តក្រចេះ និង ខេត្តស្ទឹងត្រែង។

៣- ការងារដោយឡែកៈ ការងារអភិវឌ្ឍតំបន់ព្រះវិហារ, ជួយការងាររដ្ឋលេខាធិការ ទទួលបន្ទុកគោលនយោបាយអភិបាលកិច្ចសាជីវកម្ម, គណនេយ្យ, សវនកម្ម និង អធិការកិច្ចលើកិច្ចការអធិការកិច្ច និង ជួយកិច្ចការផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន ។

**ឃ.** ឯកឧត្តម **សុខ សារាឧត្តម** អនុរដ្ឋលេខាធិការ ទទួលបន្ទុកការងារ ដូចខាងក្រោមៈ

១- ការគ្រប់គ្រងក្រសួង ស្ថាប័ន ក្នុងឋានៈជាអភិបាលហិរញ្ញវត្ថុៈ គ្រប់គ្រងការងារចំណាយ, ការងារប្រមូលចំណូល និង ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៃក្រសួង ស្ថាប័ន រួមមាន ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា- ព្រឹទ្ធសភា និងអធិការកិច្ច និង ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

២- ការគ្រប់គ្រងការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តៈ គ្រប់គ្រងការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តបាត់ដំបង និង ខេត្តបន្ទាយមានជ័យ។

៣- ការងារដោយឡែកៈ ជួយរដ្ឋមន្ត្រីក្នុងកិច្ចការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ការងារក្នុងក្របខ័ណ្ឌគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ជួយការងាររដ្ឋលេខាធិការទទួលបន្ទុកគោលនយោបាយចំណាយលើការងារថវិកា រួមទាំងការជំរុញអនុវត្តថវិកាតាមកម្មវិធី និង ការរៀបចំថវិកា និង ជួយកិច្ចការផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន។

**ង.** ឯកឧត្តម **វង់ សីលវ៉ា** អនុរដ្ឋលេខាធិការ ទទួលបន្ទុកការងារ ដូចខាងក្រោមៈ

១- ការគ្រប់គ្រងក្រសួង ស្ថាប័ន ក្នុងឋានៈជាអភិបាលហិរញ្ញវត្ថុៈ គ្រប់គ្រងការងារចំណាយ ការងារប្រមូលចំណូល និង ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៃក្រសួង ស្ថាប័ន រួមមាន ក្រសួងព័ត៌មាន និង ក្រុមប្រឹក្សាធម្មនុញ្ញ ។

២- ការគ្រប់គ្រងការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តៈ គ្រប់គ្រងការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកំពង់ចាម ខេត្តពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង។

៣- ការងារដោយឡែកៈ ការងារមហាអនុតំបន់ទន្លេមេគង្គ (GMS), បំពេញមុខងារជាអនុរដ្ឋមន្ត្រីហិរញ្ញវត្ថុកម្ពុជា នៅក្នុងកិច្ចប្រជុំអនុរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន, ជួយរដ្ឋលេខាធិការទទួលបន្ទុកការងារគោលនយោបាយអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និង ជួយកិច្ចការផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន។

ច• លោកជំទាវ **កែច ចរិយា** អនុរដ្ឋលេខាធិការ ទទួលបន្ទុកការងារ ដូចខាងក្រោមៈ

១- ការគ្រប់គ្រងក្រសួង ស្ថាប័ន ក្នុងឋានៈជាអភិបាលហិរញ្ញវត្ថុៈ គ្រប់គ្រងការងារចំណាយ, ការងារប្រមូលចំណូលនិងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៃក្រសួងសង្គមកិច្ច និង អតីតយុទ្ធជន និង ក្រសួងកិច្ចការនារី ។

២- ការគ្រប់គ្រងការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តៈ គ្រប់គ្រងការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកណ្ដាល ខេត្តកំពង់ស្ពឺ និងខេត្តតាកែវ ។

៣- ការងារដោយឡែកៈ ការងារសមាគមសិង្ហមិត្តបុគ្គលិក មន្ត្រីរាជការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ការងារយេនឌ័រ, ជួយការងារគណៈកម្មាធិការឯកជនភាវូបនីយកម្ម និងជួយកិច្ចការផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន ។

ឆ. ឯកឧត្តម **ទច់ សណ្ដាប់** អនុរដ្ឋលេខាធិការ ទទួលបន្ទុកការងារ ដូចខាងក្រោមៈ

១- ការគ្រប់គ្រងក្រសួង ស្ថាប័ន ក្នុងឋានៈជាអភិបាលហិរញ្ញវត្ថុៈ គ្រប់គ្រងការងារចំណាយ, ការងារប្រមូលចំណូល និង ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៃក្រសួង ស្ថាប័ន រួមមាន ក្រសួងបរិស្ថាន និង អង្គភាពប្រឆាំងអំពើពុករលួយ។

២- ការគ្រប់គ្រងការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុៈ គ្រប់គ្រងការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តមណ្ឌលគិរី និង ខេត្តរតនគិរី ។

៣- ការងារដោយឡែកៈ ការងារនៃគណៈកម្មាធិការគ្រប់គ្រងប្រព័ន្ធស្បៀងបំរុងកម្ពុជា, ជួយរដ្ឋលេខាធិការទទួលបន្ទុកការងារបេឡាកម្មសាធារណៈ និងជួយកិច្ចការផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន។

ឈ. ឯកឧត្តម **ហែម ចណ្ណី** អនុរដ្ឋបេខាធិការ ទទួលបន្ទុកការងារ ដូចខាងក្រោបៈ

១- ការគ្រប់គ្រងក្រសួង ស្ថាប័ន ក្នុងឋានៈអភិបាលហិរញ្ញវត្ថុៈ គ្រប់គ្រងការងារចំណាយ ការងារប្រមូលចំណូល និង ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៃក្រសួង ស្ថាប័ន រួមមាន ក្រសួងមុខងារសាធារណៈ និង អាជ្ញាធរសវនកម្មជាតិ ។

២- ការគ្រប់គ្រងការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តៈ គ្រប់គ្រងការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកោះកុង ។

៣. ការងារដោយឡែកៈ គ្រប់គ្រងការងារតំបន់ត្រីកោណ ACMEC, CLMV, ជួយរដ្ឋលេខាធិការទទួលបន្ទុកការងារគោលនយោបាយចំណាយលើការងារវិនិយោគ និង កិច្ចសហប្រតិបត្តិការអន្តរជាតិ និង ជួយកិច្ចការដទៃទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន។

**៣.** ឯកឧត្តម **ឈន សុភាព** អនុរដ្ឋលេខាធិការ ទទួលបន្ទុកការងារ ដូចខាងក្រោមៈ

១- ការគ្រប់គ្រងក្រសួង ស្ថាប័ន ក្នុងឋានៈជាអភិបាលហិរញ្ញវត្ថុៈ គ្រប់គ្រងការងារចំណាយ, ការងារប្រមូលចំណូល និង ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៃក្រសួង ស្ថាប័ន រួមមាន ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និង រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ។

២- គ្រប់គ្រងការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តៈ គ្រប់គ្រងការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខេត្តសៀមរាប និង ខេត្តប៉ៃលិន ។

៣- ការងារដោយឡែកៈ ជួយរដ្ឋមន្ត្រីក្នុងការងារនីតិកម្ម, តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅអាជ្ញាធរអប្សរា, ជួយការងាររដ្ឋលេខាធិការទទួលបន្ទុកគោលនយោបាយគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និង ជួយកិច្ចការដទៃទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន។

**៤.** ឯកឧត្តម **ស ថេន** អនុរដ្ឋលេខាធិការ ទទួលបន្ទុកការងារ ដូចខាងក្រោមៈ

១- ការគ្រប់គ្រងក្រសួង ស្ថាប័ន ក្នុងឋានៈជាអភិបាលហិរញ្ញវត្ថុៈ គ្រប់គ្រងការងារចំណាយ ការងារប្រមូលចំណូល និង ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួងធម្មការនិងកិច្ចការសាសនា និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

២- ការគ្រប់គ្រងការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តៈ គ្រប់គ្រងការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខេត្តព្រៃវែង និង ខេត្តស្វាយរៀង ។

៣- ការងារដោយឡែកៈ គ្រប់គ្រងការងារបង្រ្កាបការរត់គេចពន្ធ, ការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន និងជួយកិច្ចការដទៃទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន។

**ប្រការ២:** អនុរដ្ឋលេខាធិការ អាចជួយរដ្ឋមន្ត្រី ក្នុងការបំពេញកិច្ចការផ្សេងៗ តាមការប្រគល់សិទ្ធិរបស់រដ្ឋមន្ត្រី ។

**ប្រការ៣:** ភារកិច្ច សិទ្ធិអំណាច នីតិវិធី និង របៀបរបបបំពេញការងារប្រចាំថ្ងៃ ត្រូវអនុវត្តតាម[illegible] នៃប្រកាសលេខ ៩៤០ សហវ.ប្រក ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៣ ។

**ប្រការ៤:** ប្រកាសលេខ ៩២៧ សហវ.ប្រក ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការបែងចែកភារកិច្ចរបស់អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៥:** ឯកឧត្តម ដែលមានរាយនាមក្នុងប្រការ១ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គលេខាធិការ អគ្គនាយក នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានបុគ្គលិក គ្រប់ប្រធាននាយកដ្ឋាន និង អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តន៍តាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១៣

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ ៥ "ដើម្បីអនុវត្តន៍"
- ឯកសារ- កាលប្បវត្តិ

បណ្ឌិត.អូន ព័ន្ធមុនីរ័ត្ន